# អំណាច៩៩ភាគរយដើម្បីបញ្ឈប់ ការគ្រប់គ្រងដោយក្រុមហ៊ុនសាជីវកម្ម

សៀវភៅថ្លុកជាសេរីស្តីពី ការពង្រីកឥទ្ធិពលរបស់ក្រុមអភិជន សាជីវកម្ម និងរបៀប
ដែលប្រជាជនកសាងអំណាចរួមដើម្បីប្រឆាំងទៅនឹងពួកគេទូទាំងពិភពលោក

អំណាច៩៩ភាគរយ
ដើម្បីបញ្ឈប់ការគ្រប់គ្រង
ដោយក្រុមហ៊ុនសាជីវកម្មទៅលើ

## ប្រព័ន្ធសុខាភិបាល




ពួកយើងអស់ម៉ាស
និងធុងអុកស៊ីសែនហើយ!


ការរាតត្បាតនៃជំងឺកូវីដ-១៩ បានបង្ហាញថា
សិទ្ធិសុខភាពគឺសំខាន់បំផុត។



បិទអាជីវកម្ម
បិទ
បិទ
បិទ
បិទ បិទ បិទ
ប៉ូលីស
ជំនួយស្បៀងសហគមន៍


សម្រាប់មនុស្សជាច្រើន ជំងឺរាតត្បាតនេះបានបន្ថែមភាពលំបាកទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេផ្សេងៗគ្នា
ម៉ាក់ តើពួកយើងអាចទៅផ្ទះបាននៅ?


ជាពិសេសគឺចំពោះអ្នកដែល
រស់នៅក្នុងតំបន់ដែលរងផល
ប៉ះពាល់ដោយសារជម្លោះ
ជំងឺកូវីដ-១៩
សូមនៅផ្ទះ
លាងសម្អាត
ដៃ
មួយគ្រួសារទទួល
បានមួយលីត្រ
រក្សាគម្លាតគ្នា
៦ហ្វីត
( ១.៨ម៉ែត្រ )
ពាក់ម៉ាស
ចំណាយពេល
ដើម្បីបន្ធូរអារម្មណ៍
រក្សាគម្លាត
សង្គម






... និងចំពោះអ្នកដែលរងគ្រោះបំផុតដោយសារវិសមភាពនៃរចនាសម្ព័ន្ធ។



ពួកយើង ៩៩ភាគរយយល់ថាសុខភាពរបស់ពួកយើងគឺជាសម្បត្តិរួម
ព្រមទាំងសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់គ្នា!

ទោះជាយ៉ាងណា សម្រាប់មនុស្សមួយចំនួនតូចនៅតែយល់ថាសុខភាព
របស់ពួកយើងគឺជាទំនិញដែលអាចទិញលក់បាន។






មនុស្ស១ភាគរយបានកែប្រែសិទ្ធិសុខភាពរបស់ពួកយើងទៅជាម៉ាស៊ីន
រកប្រាក់ចំណេញទៅវិញ។

អស់ជាច្រើនទសវត្សមកហើយ ដែលក្រុមហ៊ុនសាជីវកម្មបានចាយលុយរាប់ពាន់លានដុល្លារ
ដើម្បីមានឥទ្ធិពលទៅលើបញ្ញត្តិ និងគោលនយោបាយសាធារណៈដែលវាបានផ្តល់ភាពងាយស្រួល
សម្រាប់ពួកគេក្នុងការធ្វើឯកជនភាវូបនីយកម្មទៅលើសេវាសាធារណៈសំខាន់ៗ។





ដោយសារការគ្រប់ដណ្ដប់ទៅលើការសម្រេចចិត្តរបស់រដ្ឋាភិបាលពីសំណាក់ក្រុមហ៊ុន
សាជីវកម្ម ដូចនេះប្រព័ន្ធសុខាភិបាលរបស់ពួកយើងកាន់តែមានភាពផុយស្រួយទៅៗ។

នៅពេលដែលប្រព័ន្ធសុខាភិបាល ត្រូវបានដំណើរការជាម៉ាស៊ីនរកប្រាក់ចំណេញ ក្រុមហ៊ុនសាជីវកម្មលផលិតឱសថ ក៏កំពុងដំណើរ
ដូចគ្នានៅក្រោមរូបភាពនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីដោយអំណះអំណាងថា៖ គ្មានប្រាក់ចំណេញ ស្មើនឹងគ្មានការវិនិយោគ។






នេះហើយជាមូលហេតុដែលវ៉ាក់សាំង និងការព្យាបាលមិនត្រូវបានផ្តល់ដល់សហគមន៍ក្រីក្រដែលមានហានិភ័យខ្ពស់ ចំណែកការស្រាវជ្រាវភាគច្រើន គឺផ្តោតសំខាន់តែទៅលើផលិតផលណាដែលអាចផ្តល់ប្រាក់ចំណេញនៅក្នុងប្រទេសអ្នកមានតែប៉ុណ្ណោះ។



កាលពីប៉ុន្មានទសវត្សមុន ការគ្រប់គ្រងយកពីសំណាក់ក្រុមហ៊ុនសាជីវកម្មត្រូវបានបង្កើតឡើងដោយបន្លំក្នុងរូបភាពនៃ "សេរីភាវូបនីយកម្ម" ដើម្បីអាចឱ្យពួកគេគ្រប់គ្រងដោយផ្ដាច់មុខ និងបង្កើនប្រាក់ចំណេញតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធ របស់ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នពហុភាគីពាក់ព័ន្ធផ្សេងៗទៀត។

ឧទាហរណ៍៖ កាលពី ២៥ឆ្នាំមុន ក្រុមហ៊ុនហ្វាយសឺ (Pfizer) បានបញ្ចុះបញ្ចូលរដ្ឋាភិបាលក្នុងប្រទេសអ្នកមាន ឱ្យដាក់ចេញនូវបញ្ញត្តិដើម្បីការពារសិទ្ធិកម្មសិទ្ធិបញ្ញា និងប៉ាតង់នៅអង្គការពាណិជ្ជកម្មពិភពលោក (អពព)។



# ពួកយើងជឿជាក់លើប៉ាតង់




ជាលទ្ធផល គោលនយោបាយការពារប៉ាតង់ជាតិ និងអន្តជាតិបានចាប់ផ្ដើមធ្វើឱ្យពួកយើងខាតបង់ជីវិតរបស់យើង។ ឧទាហរណ៍នៅក្នុងអំឡុងពេលមានវិបត្តិមេរោគអេដស៍(HIV/AIDS) ក្រុមហ៊ុនផលិតឱសថធំៗ បានប្រើប្រាស់អង្គការពាណិជ្ជកម្មពិភពលោក(អពព) ដើម្បីរារាំងមិនឱ្យចេញប៉ាតង់សម្រាប់ថ្នាំដែលអាចពន្យារអាយុជីវិតនៃអ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ ដែលជាហេតុនាំឱ្យជីវិតមនុស្សជាច្រើនត្រូវបានបាត់បង់។

រហូតដល់ពេលមួយដែលសង្គមស៊ីវិលទាមទារឱ្យក្រុមហ៊ុនសាជីវកម្មមូលធនទាំងនោះ ផ្តល់លទ្ធភាពក្នុងការទទួល
បានការព្យាបាលជំងឺអេដស៍ទៅក្នុងរបៀបវារៈនយោបាយសកល។






សព្វថ្ងៃនេះ ម៉ាស៊ីនរកប្រាក់ចំណេញកំពុងដំណើរការ
ក្នុងល្បឿនមួយយ៉ាងថេរ!




ក្រុមហ៊ុនសាជីវកម្មផលិតឱសថកំពុងរកប្រាក់ចំណេញបានកាន់តែច្រើនជាងពេលធម្មតាទៅទៀតអំឡុងពេលមានជំងឺរាតត្បាត។ ពួកគេទទួលបានប្រាក់រាប់ពាន់លានដុល្លារពីមូលនិធិ សាធារណៈសកល និងប្រាក់ពន្ធដើម្បីធ្វើការសិក្សាស្រាវជ្រាវវ៉ាក់សាំងកូវីដ-១៩ ខណៈមនុស្សរាប់ពាន់លានអ្នកនៅតែមានហានិភ័យក្នុងការឆ្លងមេរោគនេះ។




ចុះកិច្ចព្រមព្រៀងដែលមានតម្លៃរាប់ពាន់
លានដុល្លារដោយខ្វះតម្លាភាព




ដំដែល ក្រុមហ៊ុនសាជីវកម្មបានដាក់ពង្រាយ និងប្រើប្រាស់ការទូតសេដ្ឋកិច្ចរបស់ពួកគេនៅអង្គការពាណិជ្ជកម្មពិភពលោក (អពព) ដោយមិនបានអើពើនឹងការអំពាវនាវជាសកលឱ្យបោះបង់សិទ្ធិកម្មសិទ្ធបញ្ញាសម្រាប់វ៉ាក់សាំងកូវីដ-១៩ និងការព្យាបាលនោះទេ។

ពួកគេបានបដិសេដមិនស្ម័គ្រចិត្តចែករំលែកចំណេះដឹង និង
បច្ចេកវិទ្យាក្នុងការផលិតដែលអាចជួយពន្លឿនការផលិតវ៉ាក់សាំង។




ការពិតដ៏អាក្រក់នោះគឺថា ប្រសិនបើរដ្ឋាភិបាលនៅតែបន្តផ្តល់អាទិភាពដល់ការរកប្រាក់ចំណេញជាជាងប្រជាជននោះ សហគមន៍ដែលមានហានិភ័យជាច្រើននឹងមិនបានទទួលការចាក់វ៉ាក់សាំងនោះទេ។
វ៉ាក់សាំង
Swoosh
មានអីខ្លះនៅ?
អត់ទេ
មិនមានទេ


រដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការធានាឱ្យបាន
នូវសិទ្ធិទទួលបានសេវាសុខភាព...
ផ្ទេរប្រាក់
$


ក្រុមហ៊ុនផលិតឱសថធំៗ
ក្រុមហ៊ុនធានារ៉ាប់រង
សម្រាប់ប្រជាពលរដ្ឋទាំងអស់ដោយ
គ្មានការរើសអើង




ប៉ុន្តែ ដោយសារការគ្រប់គ្រង
យកពីសំណាក់ក្រុមហ៊ុន
សាជីវកម្ម
បុគ្គលិកសុខាភិបាល




.....ពួកគេបានអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្មក្លាយទៅជាតួអង្គដ៏មានឥទ្ធិពលក្នុងការធ្វើការសម្រេចចិត្តទៅលើសុខភាពរបស់ពួកយើង។




ស្របពេលជាមួយគ្នានេះដែរ វិសមភាពនៅក្នុងវិស័យសុខាភិបាល
កាន់តែបន្តពង្រីក និងបានបែងចែកប្រជាជនទៅជាអ្នកដែលអាច
មានលទ្ធភាពទិញសុខភាព និងអ្នកដែលមិនមានលទ្ធភាពទិញ។




នៅជុំវិញពិភពលោក អ្នកដែលរងប៉ះពាល់ច្រើនជាងគេដោយសាររចនាសម្ព័ន្ធសេដ្ឋកិច្ច ការរើសអើង
ជាតិសាសន៍ វិសមភាពយេនឌ័រ គឺរឹតតែងាយរងគ្រោះធ្ងន់ធ្ងរបន្ថែមទៀតទៅលើសុខភាពពួកគេ ស្រប
ពេលដែលយើងមានប្រព័ន្ធសុខាភិបាលដែលផុយស្រួយ ជាពិសេសគឺអំឡុងពេលមានជំងឺរាតត្បាត។



ប៉ុន្តែនៅទូទាំងសកលលោក សំលេងរបស់ប្រជាជនកំពុងតែកើនឡើងដោយ
បានអះអាងថាពួកយើងគឺជាម្ចាស់កម្មសិទ្ធិ មិនមែនអតិថិជននោះទេ....



….. និងកំពុងចងក្រងដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់សង្គមមួយដែលប្រាកដថាសុខុមាលភាពរបស់ ប្រជាជន ៩៩ភាគរយស្ថិតនៅចំកណ្ដាលនៃគោលនយោបាយសាធារណៈ និងប្រព័ន្ធសុខាភិបាល។


ប្រសិនបើអ្នកមានអារម្មណ៍ថាមិន
ពេញចិត្ត និងធុញទ្រាន់ដោយសារការ
ប្រែក្លាយសុខភាពទៅជាទំនិញ
ដោយក្រុមហ៊ុនសាជីវកម្ម សូមចូលរួម
ជាមួយពួកយើងដើម្បី .....


សុខភាព
របស់យើង
មិនមែន
សម្រាប់លក់
នោះទេ
សុខភាព
ជាជាងប្រាក់
ចំណេញ
សិទ្ធិទទួល
បានសេវា
សុខភាព
បញ្ឈប់ការគ្រប់គ្រងយក
ពីសំណាក់ក្រុមហ៊ុន
សាជីវកម្ម!
សុខភាព
របស់យើង
មិនមែន
សម្រាប់លក់
នោះទេ
សិទ្ធិទទួលបាន
សេវាសុខភាព

# សូមរង់ចាំទស្សនាវគ្គបន្ទាប់របស់ពួកយើងអំពីការគ្រប់គ្រងយកពីសំណាក់ក្រុមហ៊ុនសាជីវកម្ម និងចូលទៅកាន់ ESCR-NET ដើម្បីស្វែងយល់បន្ថែម

ថ្លែងអំណរគុណទៅដល់សមាជិក ESCR-Net ដែលតស៊ូប្រឆាំងនឹងក្រុមហ៊ុនសាជីវកម្មជុំវិញពិភពលោក ដែលមានការវិភាគ និងសកម្មភាពរួមគ្នាមួយដើម្បីបង្កើតរូបត្ថុកកំប្លែងនេះឡើង។

الشبكة العالمية
للحقوق الاقتصادية
والاجتماعية والثقافية

ESCR-Net
Red-DESC
Réseau-DESC

រចនារូបភាព៖ ហ្សាហ្គូ ប្រូដើរស

បកប្រែជាភាសាខ្មែរដោយ៖
អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ

Translated by:
SOCIAL ACTION FOR COMMUNITY AND DEVELOPMENT